# ៤ កាត់បន្ថយកត្តាគំរាមកំហែង ចំពោះសត្វព្រៃ និងទីជម្រក

ក្រុមពង្រឹងការអនុវត្តន៍ច្បាប់របស់គម្រោងព្រៃទេសភាពភាគខាងកើត អនុវត្តយុទ្ធសាស្ត្របង្កា និងទប់ស្កាត់ក្នុងការការពារជីវចម្រុះនៅក្នុងតំបន់នៃព្រៃការពារមណ្ឌលគិរី និងដែនជម្រកសត្វព្រៃភ្នំព្រេចៈ


© WWF-Cambodia / Keo Sopheak

- សមាជិកក្រុមចល័តបង្ក្រាប មានសមាជិកមកពីរដ្ឋបាលព្រៃឈើ ក្រសួងបរិស្ថាន នគរបាលព្រំដែនគោក ធ្វើការល្បាតក្រៅតំបន់ការពារក្នុងខេត្តមណ្ឌលគិរីដើម្បីទប់ស្កាត់ចរាចរសត្វព្រៃ និងឈើខុសច្បាប់ ។
- ក្រុមល្បាតជាច្រើនក្រុមមានសមាជិកមកពីរដ្ឋបាលព្រៃឈើ ក្រសួងបរិស្ថាន នគរបាលព្រំដែនគោក និងមន្ត្រីល្បាតសហគមន៍ ដើរល្បាតជាប្រចាំក្នុងតំបន់ការពារដើម្បីបញ្ឈប់ការបរបាញ់ ការកាប់ឈើ និងសកម្មភាពខុសច្បាប់ដទៃផ្សេងទៀត ។
- កិច្ចខិតខំប្រឹងប្រែងពង្រឹងការអនុវត្តន៍ច្បាប់ក្នុងព្រៃទេសភាពភាគខាងកើត ទទួលបានការគាំទ្រពីសហគមន៍មូលដ្ឋានដែលជាអ្នកផ្តល់ពត៌មានសំខាន់ៗអំពីបទល្មើសព្រៃឈើ និងសត្វព្រៃទៅកាន់ក្រុមពង្រឹងការអនុវត្តន៍ច្បាប់ ។
- ក្នុងអំឡុងពេលប៉ុន្មានឆ្នាំកន្លងទៅនេះ សកម្មភាពពង្រឹងការអនុវត្តន៍ច្បាប់នៅក្នុងតំបន់ព្រៃទេសភាព បានឃាត់ខ្លួនអ្នកកាប់ឈើ និងអ្នកជួញដូរសត្វព្រៃខុសច្បាប់ជាច្រើនរូប រឹបអូសបានរណាយន្តច្រើនគ្រឿង និងប្រភេទឈើប្រណិតរាប់រយម៉ែត្រគូប និងដកហូតបាននូវសត្វព្រៃ ( មានរស់ មានស្លាប់ ) ច្រើនប្រភេទដែលក្នុងនោះមានសត្វប្រភេទជិតផុតពូជមួយចំនួនផងដែរ ។


© WWF-Cambodia / Keo Sopheak


© WWF-Cambodia / Rohit Singh


© Tony Maling / WWF-Cambodia

## អ្នកអាចចូលរួមក្នុងសកម្មភាពអភិរក្សតាមរយៈ

- ស្នាក់នៅផ្ទះលំហែសហគមន៍ដេរអេដើម្បីគយគន់ទេសភាពធម្មជាតិ និងព្រៃឈើដ៏ស្រស់ត្រកាលនៃខេត្តមណ្ឌលគិរី! សម្រាប់ពត៌មានបន្ថែម សូមទាក់ទងទៅកាន់ CCBEN តាមរយៈ ទូរស័ព្ទ: ០២៣ ៣៩៥ ២៧២ ឬអ៊ីម៉ែល: info@ccben.org
- គាំទ្រការចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាន តាមរយៈការទិញផលិតផលកែច្នៃចេញពីអនុផលព្រៃឈើ ដូចជា: ទឹកឃ្មុំ ឬផ្តៅ ។ សម្រាប់ពត៌មានបន្ថែមស្តីអំពីទឹកឃ្មុំព្រៃខេត្តមណ្ឌលគិរី ឬក៏ផ្តៅ សូមទាក់ទងទៅកាន់:
  - NTFP-EP: ០២៣ ៧២៧ ៤០៧ ឬ ntfp-marketing@online.com.kh
  - សមាគមផ្តៅកម្ពុជា: ០១២ ៤០ ២៧ ២៤ ឬ គេហទំព័រ www.rattancambodia.com
- សូមកុំទិញផលិតផលឈើប្រណិត ឬសាច់សត្វព្រៃ ! ប្រសិនបើអ្នកបានឃើញនូវការលក់សាច់សត្វព្រៃ ឬក៏មានការសង្ស័យចំពោះសកម្មភាពល្មើសច្បាប់ណាមួយពាក់ព័ន្ធនឹងបទល្មើសព្រៃឈើ ឬសត្វព្រៃនៅក្នុងខេត្តមណ្ឌលគិរី ដូចជា: ការកាប់ឈើ ការជួញដូរ ការបរបាញ់ ឬការធ្វើចរាចរឈើ និងសត្វព្រៃខុសច្បាប់ សូមទាក់ទងទៅកាន់ក្រុមអាជ្ញាធរមានសមត្ថកិច្ច តាមទូរស័ព្ទ: ០១២ ៤០ ៤១ ៤៣ ។

ឧបត្ថម្ភថវិកាដោយ: Humanscale, Habitat Grup Empresarial, October Hill Foundation, Darwin Initiatives, US Fish and Wildlife Service.

WWF មហាតំបន់មេគង្គ - ការិយាល័យកម្មវិធីអភិរក្សនៅកម្ពុជា
ផ្ទះលេខ ២១ ផ្លូវលេខ ៣២២ សង្កាត់បឹងកេងកង១ ភ្នំពេញ ប្រអប់សំបុត្រលេខ ២៤៦៧
ទូរស័ព្ទ: ០២៣ ២១៨ ០៣៤ ទូរសារ: ០២៣ ២១១ ៩០៩
គេហទំព័រ: cambodia.panda.org

© Production February 2011 WWF-Cambodia. All rights reserved.

WWF BROCHURE 2011

# តំបន់ទេសភាពដ៏ស្រស់ត្រកាលនៃបណ្តុំព្រៃល្បោះភាគខាងកើតកម្ពុជា

តំបន់ព្រៃទេសភាពភាគខាងកើតគ្របដណ្តប់លើផ្ទៃដីប្រមាណ ៣០,០០០ គីឡូម៉ែត្រការ៉េក្នុងខេត្តចំនួន ៤ ( រតនៈគិរី មណ្ឌលគិរី ស្ទឹងត្រែង និងក្រចេះ ) ហើយបង្កើតបានជាបណ្តុំព្រៃទេសភាពធំជាងគេបង្អស់នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ។ បណ្តុំព្រៃធម្មជាតិនៅក្នុងខេត្តមណ្ឌលគិរីភាគឥសាន្តនៃប្រទេសកម្ពុជា គឺជាបេះដូងនៃតំបន់ព្រៃទេសភាពភាគខាងកើត ហើយត្រូវបាន អង្គការ WWF ទទួលស្គាល់ជាតំបន់ដែលមានតម្លៃខ្ពស់ផ្នែកជីវចម្រុះជាងគេបង្អស់មួយក្នុងចំណោមតំបន់អេកូឡូស៊ីសាកលចំនួន ២០០ ។ ព្រៃការពារមណ្ឌលគិរី ( ផ្ទៃក្រលា ៣៦៣,១៧៧ ហិកតា ) និងដែនជម្រកសត្វព្រៃភ្នំព្រេច ( ផ្ទៃក្រលា ២២២, ៥០០ ហិកតា ) ជាតំបន់ការពារសំខាន់ពីរនៃខេត្តមណ្ឌលគិរី សម្បូរទៅដោយទីជម្រកច្រើនប្រភេទ រាប់ចាប់ពីព្រៃស្រោង ពាក់កណ្តាលស្រោង រហូតដល់ព្រៃល្បោះ ហើយវាគាំទ្រដល់ការរស់នៅរបស់ពពួកសត្វប្រភេទជិតផុតពូជជាច្រើន ដូចជា: ដំរីអាស៊ី ខ្លាធំ ខ្លារខិន ទន្សោង ក្រពើភ្នំ ខ្ទីង ក្របីព្រៃ និងរមាំង ព្រមទាំងពពួកសត្វស្លាបប្រភេទជិតផុតពូជជាច្រើនទៀត ។


© GDANCP / WWF-Cambodia


© FA / WWF-Cambodia


© GDANCP / WWF-Cambodia


© WWF-Cambodia / Tep Asnarith


© WWF-Cambodia / Nick Cox


© WWF-Cambodia / Nick Cox

## គម្រោងព្រៃទេសភាពភាគខាងកើត

ដោយសហការណ៍ជាមួយរដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន អង្គការ WWF កម្ពុជា បានបង្កើតគម្រោងព្រៃទេសភាពភាគខាងកើតឡើងដើម្បីឆ្លើយតបទៅនឹងកត្តាគំរាមកំហែងចំពោះតំបន់នេះ និងក្នុងគោលដៅអភិរក្សជីវចម្រុះដ៏មានតម្លៃជាលក្ខណៈសាកលនៅក្នុងតំបន់នេះ ។ ដើម្បីអភិរក្សជីវចម្រុះនៅក្នុងខេត្តមណ្ឌលគិរី គម្រោងផ្តោតការងារគ្រប់គ្រងលើតំបន់សំខាន់ៗចំនួនពីរ ហើយបាន និងកំពុងអនុវត្តយ៉ាងសកម្មនូវការងារលើកកម្ពស់ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព ការរៀបចំធ្វើផែនការប្រើប្រាស់ដីធ្លី ការបង្ការ និងទប់ស្កាត់បទល្មើសព្រៃឈើ និងសត្វព្រៃនៅទូទាំងខេត្តមណ្ឌលគិរីទាំងមូលផងដែរ ។

## ទស្សនៈវិស័យ

ថែរក្សា និងការពារបណ្តុំព្រៃទេសភាព និងជីវចម្រុះរបស់កម្ពុជា ឱ្យនៅស្រស់ត្រកាល ហើយតភ្ជាប់គ្នា និងជួយប្រជាជនក្នុងការការពារធនធានព្រៃឈើ និងសត្វព្រៃ ព្រមទាំងលើកកម្ពស់ការចិញ្ចឹមជីវិតរបស់ពួកគេប្រកបដោយនិរន្តរភាព ។



## ការគំរាមកំហែង

ជីវចម្រុះដ៏សម្បូរបែបរបស់តំបន់ព្រៃទេសភាពភាគខាងកើត កំពុងស្ថិតក្រោមការគំរាមកំហែងដោយសារ ការកាប់ឈើខុសច្បាប់ ការបរបាញ់សត្វព្រៃសម្រាប់ធ្វើអាជីវកម្ម ការរានយកដីព្រៃដើម្បីធ្វើកសិកម្ម និងដើម្បីសាងសង់លំនៅដ្ឋាន ព្រមទាំងការប្រើប្រាស់ធនធានធម្មជាតិមិនមាននិរន្តរភាព។ អាជីវកម្មរុករករ៉ែ និងការអភិវឌ្ឍន៍វារីវប្បកម្ម ជាកត្តាគំរាមកំហែងធ្ងន់ធ្ងរបន្ថែមចំពោះធនធានព្រៃឈើ និងសត្វព្រៃ។ ប្រភេទសត្វព្រៃដ៏មានតម្លៃ និងជាប្រភេទសត្វអត្តសញ្ញាណជាតិដូចជា គោព្រៃ ប្រហែលបានផុតពូជទៅហើយ។ ចំណែកឯសត្វខ្លាធំ ដំរីអាស៊ី ក្របីព្រៃ និងរមាំង កំពុងទទួលរងការគំរាមកំហែងអាចឈានទៅផុតពូជនៅប៉ុន្មានឆ្នាំខាងមុខនេះ ប្រសិនបើពុំមានវិធានការសមស្របបន្ទាន់ទេនោះ។

## សកម្មភាពគម្រោង

ដើម្បីសម្រេចបាននូវគោលដៅ និងទស្សនៈវិស័យលើការងារអភិរក្ស ក៏ដូចជាលើកកម្ពស់ការចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋានដែលរស់នៅក្នុង និងជុំវិញតំបន់ការពារ គម្រោងតំបន់ព្រៃទេសភាពភាគខាងកើត បាន និងកំពុងអនុវត្តនូវសកម្មភាពសំខាន់ៗជាច្រើនៈ

## ១ ការលើកកម្ពស់ការគ្រប់គ្រងធនធានធម្មជាតិ ដោយមានការចូលរួមពីសហគមន៍ ការអប់រំ និងបង្កើនការយល់ដឹងស្ដីអំពីការអភិរក្ស

នៅក្នុងតំបន់ព្រៃទេសភាពភាគខាងកើត ការអប់រំ និងការបង្កើនការយល់ដឹងស្ដីពីការងារអភិរក្ស ដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើនចំណេះដឹងរបស់សហគមន៍មូលដ្ឋាន ទាំងចាស់ ទាំងក្មេង ស្ដីអំពីកិច្ចការពារបរិស្ថាន និងសារៈសំខាន់នៃការងារអភិរក្ស ព្រមទាំងលើកទឹកចិត្តពួកគេឱ្យចូលរួមក្នុងការការពារធនធានព្រៃឈើ និង សត្វព្រៃ។ ភាគច្រើននៃប្រជាជនរស់នៅក្នុងតំបន់ព្រៃទេសភាពសរុបប្រមាណ ៤000 គ្រួសារ រស់នៅក្នុងសហគមន៍ចំនួន ៥ សុទ្ធសឹងជាជន ជាតិដើមភាគតិច ដែលរស់នៅដោយពឹងផ្អែកលើធនធាននៅក្នុងព្រៃអស់រយៈពេលជាច្រើនសតវត្សរ៍មកហើយរហូតមកទល់ពេលនេះ។ បច្ចុប្បន្ន ការចិញ្ចឹមជីវិតរបស់ពួកគេកំពុងរងការគំរាមកំហែង ដោយសារសកម្មភាពផ្សេងៗដែលមិនធានានិរន្តរភាពសម្រាប់ធនធានធម្មជាតិ។

មកទល់ពេលបច្ចុប្បន្ន ដោយសារមានកិច្ចខិតខំប្រឹងប្រែងរបស់គម្រោង ក្រោមកិច្ចសហការណ៍ជាមួយរាជរដ្ឋាភិបាល និងអង្គការជាដៃគូរ សមាជិកសហគមន៍មួយចំនួនធំមានការយល់ដឹងយ៉ាងច្បាស់អំពីអត្ថប្រយោជន៍នៃការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាពចំពោះជីវភាពរស់នៅរបស់ពួកគេ និងកូនចៅជំនាន់ក្រោយៗទៀត។ គម្រោងសម្រេចបាននូវសមិទ្ធផលជាច្រើនក្នុងកិច្ចការលើកកម្ពស់ការចិញ្ចឹមជីវិតរបស់សហគមន៍តាមរយៈ ការជួយជ្រោមជ្រែងពួកគេក្នុងការបង្កើតបានជាក្រុមសហគមន៍ប្រើប្រាស់អនុផលព្រៃឈើដោយនិរន្តរភាព ដូចជា ក្រុមប្រមូលទឹកឃ្មុំ ជ័រទឹក ព្រមទាំងក្រុមសហគមន៍នេសាទ និងក្រុមសហគមន៍ព្រៃ និងតំបន់ការពារធម្មជាតិ។



© Sroun Vanny / WWF-Cambodia



© WWF-Cambodia / Amy Maling



© Femy Pinto / WWF-Cambodia



© WWF-Cambodia

## ២ ការអភិវឌ្ឍន៍វិស័យទេសចរណ៍ធម្មជាតិដើម្បីលើកកម្ពស់ការចិញ្ចឹមជីវិត និងការអភិរក្ស

អង្គការ WWF បានកំណត់យកការអភិវឌ្ឍន៍វិស័យទេសចរណ៍ធម្មជាតិ ជាយុទ្ធសាស្ដ្រមួយសម្រាប់លើកកម្ពស់ជីវភាពសហគមន៍រស់នៅជុំវិញតំបន់ការពារ ព្រមទាំងរួមចំណែកគាំទ្រផ្នែកថវិកាដល់ការងារគ្រប់គ្រងតំបន់ការពារធម្មជាតិ។ គម្រោងបានបំពាក់បំប៉ននូវចំណេះដឹង និងជំនាញដល់សមាជិកសហគមន៍ពាក់ព័ន្ធនឹងការគ្រប់គ្រងសកម្មភាពទេសចរណ៍ បដិសណ្ឋារកិច្ច ចម្អិនអាហារ នាំភ្ញៀវទស្សនាតំបន់ និងការងារតម្បាញ។



© GDANCP / WWF-Cambodia



© WWF-Cambodia / Eng Mengey

បច្ចុប្បន្ន ទេសចរអាចរីករាយជាមួយនឹងសេវាកម្មផ្សេងៗ ដែលមានដំណើរការនៅក្នុងតំបន់ព្រៃទេសភាពរួមមានៈ ការស្នាក់នៅផ្ទះលំហែសហគមន៍ ការដើរ និងជិះកង់ក្នុងព្រៃកំសាន្ត ការជិះទូកលេង ព្រមទាំងការដើរកំសាន្តតាមផ្ទះអ្នកភូមិមូលដ្ឋានដើម្បីស្វែងយល់អំពីវប្បធម៌របស់ជនជាតិដើមភាគតិចពួង។ ក្រោមការជ្រោមជ្រែងផ្នែកបច្ចេកទេសពី អង្គការ WWF គម្រោងផ្ទះលំហែសហគមន៍ស្ថិតក្រោមការគ្រប់គ្រងផ្ទាល់ដោយក្រុមសហគមន៍ទេសចរណ៍ធម្មជាតិមានសមាជិកជាជនជាតិដើមភាគតិចពួង តំណាងឱ្យ ១៣ គ្រួសារ។



© WWF-Cambodia



© WWF-Cambodia / Meo Samorn

ជាមួយគ្នានេះដែរ គម្រោងបានបញ្ចប់រួចរាល់ហើយនូវការសាងសង់ផ្ទះលំហែលំដាប់ទំនើបដែលមានទីតាំងស្ថិតនៅតាមដងទន្លេស្រែពកក្នុងព្រៃការពារមណ្ឌលគិរី។ បច្ចុប្បន្ន គម្រោងកំពុងរៀបចំការតុបតែង និងបំពាក់នូវគ្រឿងបរិក្ខានៅផ្នែកខាងក្នុង។ គេនឹងសម្ពោធដាក់ឱ្យដំណើរការនូវផ្ទះលំហែលំដាប់ទំនើបនេះនៅក្នុងខែ មិនា ឆ្នាំ ២០១១។ ការគ្រប់គ្រងដំណើរការផ្ទះលំហែលំដាប់ទំនើបនេះនឹងប្រគល់ជូនរដ្ឋបាលព្រៃឈើ ដោយមានការសហការណ៍ជាមួយក្រុមហ៊ុនឯកជន។ ផ្ទះលំហែនេះនឹងផ្ដល់ឱកាសការងារសម្រាប់សហគមន៍ ព្រមទាំងលើកទឹកចិត្តឱ្យអ្នកភូមិ និងភ្ញៀវទេសចរបានចូលរួមអភិរក្ស និងគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។



© I Ching Decor / WWF-Cambodia



© I Ching Decor / WWF-Cambodia

## ៣ ការស្រាវជ្រាវជីវចម្រុះខេត្តមណ្ឌលគិរីដើម្បីប្រសិទ្ធិភាពការគ្រប់គ្រង

ចំណេះដឹងស្ដីអំពីសត្វព្រៃ ជាមូលដ្ឋានគ្រឹះសំខាន់មួយដើម្បីឈានទៅយល់ដឹងពីស្ថានភាពរបស់ពួកវា ព្រមទាំងធ្វើផែនការគ្រប់គ្រង និងអភិរក្សទៀតផង។ នេះគឺជាមូលហេតុមួយដែល អង្គការ WWF បានចាប់ផ្ដើមអនុវត្តគម្រោងស្រាវជ្រាវមួយចំនួនក្នុងតំបន់ព្រៃទេសភាពភាគខាងកើតដើម្បីទទួលបាននូវពតិមានបន្ថែមអំពីតម្លៃជីវចម្រុះរបស់ព្រៃការពារមណ្ឌលគិរី និងដែនជម្រកសត្វព្រៃភ្នំព្រេច។

- ម៉ាស៊ីនថតរូបស្វ័យប្រវត្តិចំនួនជាង ១៧0 ដែលត្រូវបានបំពាក់នៅព្រៃក្នុងតំបន់ការពារ បានផ្ដល់ឱ្យអ្នកស្រាវជ្រាវរបស់អង្គការ WWF នូវពតិមានអំពីសត្វព្រៃ និងស្ថានភាពរបស់ពួកវា។
- ការស្រាវជ្រាវដោយវិធីសាស្ត្របន្ទាត់ត្រង់ស៊ុកត្រូវបានអនុវត្តជាប្រចាំដើម្បីប្រមូលទិន្នន័យប្រភេទសត្វក្រចកជើងពីរធំៗដូចជា ទន្សោង ខ្ទីង និងរមាំង ដែលជាចំណីដ៏សំខាន់សម្រាប់សត្វខ្លាធំដែលមានវត្តមាននៅក្នុងតំបន់ព្រៃទេសភាពភាគខាងកើត។
- អង្គការ WWF នាពេលថ្មីៗនេះបានអនុវត្តនូវការស្រាវជ្រាវលម្អិតដើម្បីប៉ាន់ប្រមាណចំនួនសត្វ ដំរីអាស៊ី ខ្លាធំ ខ្លារខិន ក្រពើភ្នំ និងទោចថ្គាល់លឿង។



© WWF-Cambodia / Eng Mengey



© UW Center for Conservation Biology / WWF-Cambodia